ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ៖ ២៧
ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០
សាលក្រមលេខ៖ ១៥២ "ក១"
ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

# សាលក្រម
## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

-បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២០ លើសំណុំរឿងរដ្ឋប្បវេណីលេខ៖២៧ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ។

**ដោយមានសមាសភាពដូចតទៅ**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

រវាងដើមចោទឈ្មោះ [redacted] ថៃ ភេទស្រី អាយុ៣៧ឆ្នាំ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅ [redacted] ។

មានមេធាវីលោក [redacted] អាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ [redacted] ។

ចុងចម្លើយឈ្មោះ [redacted] **ពុធមិសាល** អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

មេធាវីតំណាងដោយអាណត្តិអោយដើមចោទ៖ [redacted]

ចុងចម្លើយឈ្មោះ [redacted] **ហឿន** ភេទប្រុស, ឈ្មោះ [redacted] **ចាន់សាវី** ,ឈ្មោះ [redacted] **វិបុល** ភេទប្រុស អាសយដ្ឋាន [redacted] ។

## I. អង្គហេតុ និងចំណុចវិវាទ

### ១.ខ្លឹមសារនៃសាលក្រមដែលភាគីទាមទារឲ្យតុលាការចេញ

**១.១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ៖**

-សុំបញ្ឈប់ការអនុវត្ត និងលុបចោលដីកាសម្រេចរក្សាការពារលេខ៖ ២៥១ "ក១"ដរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាមោឃៈ ។

-ប្រគល់ចលនទ្រព្យ(រថយន្ត) ម៉ាក TOYOTA CAMRY ពាក់ស្លាកលេខ ភ្នំពេញ ២AG-៥១៨០ ពណ៌ទឹកមាស ផលិតឆ្នាំ២០០៧ លេខតួ ០០៨៧៤៤ លេខម៉ាស៊ីន ២៣២២៤៦ ដែលបានធ្វើការរឹបអូសរួចគ្រលប់មក អោយដើមចោទឈ្មោះ ស្រ៊ាន់ ថៃ ជាអ្នកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងវិញ ។

-សុំអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុច០១ និង០២ នៃការទាមទារ

-បង្គាប់ឲ្យសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា សោហ៊ុយសេវាកម្មផ្នែកច្បាប់ សរុបចំនួន USD ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ពីសហចុងចម្លើយ ។

-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

១.២ ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយទាមទារឱ្យតុលាការចេញ៖

-គ្មាន ។

## ២.ការពន្យល់គ្រួសៗអំពីរឿងក្តី

ចុងចម្លើយឈ្មោះ [redacted] **ពុធវិសាល** បានប្តឹងសុំដីសម្រេចរក្សាការពារហាមឃាត់ រថយន្តមួយគ្រឿងម៉ាក TOYOTA CAMRY ពណ៌ ទឹកមាស លេខតួ 0008744 ផលិតឆ្នាំ ២០០៧ ស្លាកលេខ៖ 2AG-5180 ដោយហេតុថាចុងចម្លើយឈ្មោះ [redacted] វិបុល, ឈ្មោះ [redacted] ចាន់សារី និងឈ្មោះ [redacted] ហឿន បានជំពាក់ប្រាក់របស់ខ្លួន ។ នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាសាលា បានចុះរឹបអូសរថយន្តមួយគ្រឿងម៉ាក TOYOTA CAMRY ពណ៌ ទឹកមាស លេខតួ 0008744 ផលិតឆ្នាំ ២០០៧ ស្លាកលេខ៖ 2AG-5180 តាមដីកាសម្រេចរក្សាការពារលេខ៖ ២៥១ "ក១" ង.រ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ ។ ប៉ុន្តែរថយន្តនោះ ដើមចោទឈ្មោះ [redacted] ថៃ អះអាងថាជារបស់ខ្លួន ដែលចុងចម្លើយឈ្មោះ [redacted] វិបុល បានទិញបង់រំលោះក្នុងតម្លៃ USD ៣៥០០០ (បីម៉ឺនប្រាំពាន់ ដុល្លារអាមេរិក) ។ បច្ចុប្បន្នចុងចម្លើយឈ្មោះ [redacted] វិបុល បង់បានត្រឹម USD ៣០០០០ (បីម៉ឺនដុល្លារអាមេរិក) ដែលនៅមិនទាន់គ្រប់ចំនួននៅឡើយ ទើបខ្លួនប្តឹងសុំតវ៉ាចូលជាតតិយជន ដើម្បីលុបចោលការអនុវត្តដីកាសម្រេចរក្សាការពារ ។

## ៣.អង្គហេតុដែលអះអាងដោយដើមចោទ

លោកមេធាវី [redacted] បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនជាមេធាវីតំណាងអោយដើមចោទខ្លួនសុំរក្សាសេចក្តីថ្លែងការណ៍នានីតិវិធីត្រៀមលើកទី១ និងពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ ដែលមានខ្លឹមសារនៃការទាមទារ៖

១.សុំបញ្ឈប់ការអនុវត្ត និងលុបចោលដីកាសម្រេចរក្សាការពារលេខ៖ ២៥១ "ក១"ងរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាមោឃៈ ។

២.ប្រគល់ចលនទ្រព្យ(រថយន្ត) ម៉ាក TOYOTA CAMRY ពាក់ស្លាលកលេខ ភ្នំពេញ ២AG-៥១៨០ ពណ៌ទឹកមាស ផលិតឆ្នាំ២០០៧ លេខតួ ០០៨៧៤៤ លេខម៉ាស៊ីន ២៣២២៤៦ ដែលបានធ្វើការរឹបអូសរួចត្រលប់មក អោយដើមចោទឈ្មោះ [redacted] ថៃ ជាអ្នកមានសិទ្ធិចាត់ចែង និងគ្រប់គ្រងវិញ។

៣.សុំអនុវត្តជាបណ្តោះអាសន្នត្រង់ចំណុច០១ និង០២

៤.បង្គាប់ឱ្យសងសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា សោហ៊ុយសេវាកម្មផ្នែកច្បាប់ សរុបចំនួន USD ៥.០០០ (ប្រាំពាន់) ដុល្លារអាមេរិក ពីសហចុងចម្លើយ ។

៥.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ ។

មូលហេតុនៃការប្តឹងសុំគឺ ចុងចម្លើយបានទិញរថយន្តពីកូនក្តីខ្លួននៅឆ្នាំ២០១៥ ហើយកាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ លោក [redacted] អាជ្ញាសាលានៃសាលាដំបូង រាជធានីភ្នំពេញ បានដឹកនាំគណៈកម្មការ ចុះអនុវត្តដីកាសម្រេចរក្សាការពារលេខ៖ ២៥១ "ក១"ងរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២០ ដោយរឹបអូសបណ្តោះអាសន្នចលនវត្ថុរថយន្តមួយគ្រឿង ម៉ាក TOYOTA CAMRY ពាក់ស្លាកលេខ ភ្នំពេញ ២AG-៥១៨០ ពណ៌ទឹកមាស ផលិតឆ្នាំ២០០៧ លេខតួ ០០៨៧៤៤ លេខម៉ាស៊ីន ២៣២២៤៦ ដែលបានអះអាងថាជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] ចាន់សារី ប៉ុន្តែជាក់ស្តែងរថយន្តនេះកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៥ កូនក្តីខ្លួនបានលក់រថយន្តបង់រំលួសមានការប្រាក់ តែគ្មានទ្រព្យបញ្ចាំអោយទៅឈ្មោះ [redacted] វិបុល ក្នុងតម្លៃ USD ៣៥.០០០ (បីម៉ឺនប្រាំពាន់)ដុល្លារអាមេរិក កក់មុន USD ៥០០០ (ប្រាំពាន់ដុល្លារអាមេរិក) ដូច្នេះតម្លៃរថយន្តបូក ទាំងប្រាក់ និងការប្រាក់ សរុបមានចំនួនUSD ៥២.៥០០ (ប្រាំម៉ឺន ពីរពាន់ប្រាំរយដុល្លារអាមេរិក) ហើយឈ្មោះ [redacted] វិបុល ត្រូវបង់ប្រាក់រំលួសក្នុងមួយខែ USD ៦០០ (ប្រាំមួយរយដុល្លារអាមេរិក) រហូតដល់គ្រប់ចំនួន តែបច្ចុប្បន្នទើប តែបង់បាន USD ៣០.០០០ (បីម៉ឺនដុល្លារអាមេរិក) គឺនៅមិនទាន់បង់គ្រប់ចំនួននៅឡើយ ។ ដូចនេះរថយន្តគឺជារបស់កូនក្តីខ្លួនពុំមិនមែនជាកម្មសិទ្ធិរបស់សហចុងចម្លើយឈ្មោះ [redacted] ហឿន និង [redacted] ចាន់សារី និង [redacted] វិបុល ទេ ។ ចុងចម្លើយឈ្មោះ [redacted] ពុធវិសាល មិនបានប្តឹងសុំ

រឹបអូសយករថយន្តដែលជាកម្មសិទ្ធិរបស់កូនក្តីខ្ញុំបាទដើម្បីទុកសម្រាប់ ធានាបំណុលរបស់ខ្លួនបានឡើយ ព្រោះវាជាករណីវិវាទជាមួយសហចុងចម្លើយឈ្មោះ [redacted] ហឿន , [redacted] ចាន់សារី និងឈ្មោះ [redacted] វិបុល តែប៉ុណ្ណោះ ។ ហេតុនេះសូមតុលាការសម្រេចតាមការប្តឹងសុំរបស់កូនក្តីខ្លួន ។

**៥.អង្គហេតុដែលអះអាងដោយចុងចម្លើយ**

-លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយឈ្មោះ [redacted] **ពុធវិសាល** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ការប្តឹងសុំតវ៉ារបស់តតិយជនឃើញថាមិនត្រឹមត្រូវតាមច្បាប់ ។ ចំពោះរថយន្តគឺឈ្មោះ [redacted] វិបុល បានទិញបង់រំលោះយូរឆ្នាំហើយ និងបានបង់ការប្រាក់លើសថ្លៃរថយន្តទៀត ចំពោះសិទ្ធិលើបំណុលលើឈ្មោះ [redacted] វិបុល កូនក្តីខ្លួននៅមានសិទ្ធិលើបំណុលដែលបានរក្សាការពារដដែល ។ ដូចនេះសុំច្រានចោលការប្តឹងសុំចូលជាតតិយជនរបស់ដើមចោទ និងសុំតំកល់ដីកាសម្រេចរក្សាការពារទុកជាបានការដដែល ។

-ចុងចម្លើយ [redacted] **វិបុល** បានធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនជាតំណាងអោយ [redacted] ហឿន (ស្លាប់) និងឈ្មោះ [redacted] ចាន់សារី ព្រោះម្តាយខ្លួនគាត់ឈឺមិនអាចមកបានទេ ។ ខ្លួនមិនមានការជំទាស់ទេ ដូចនេះរាល់ការសម្រេចសេចក្តីស្នើសុំតុលាការសម្រេចតាមច្បាប់ ។

**៦.ចំណុចវិវាទ**

-តើការប្តឹងសុំចូលជាតតិជនរបស់ដើមចោទមានមូលហេតុត្រឹមត្រូវដែរឬទេ?

**៧.ចំណុចគ្មានវិវាទ**

-គ្មាន ។

## II.ការពិនិត្យភស្តុតាង

**១.ភស្តុតាងជាឯកសាររបស់ដើមចោទ**

-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៧

-បណ្ណ័សម្គាល់យានយន្ត ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៧

-តារាងបង់ប្រាក់

-លិខិតឆ្លងដែនរបស់លោកស្រី [redacted] KOSITATSAWAPOL

**២.ភស្តុតាងជាឯកសាររបស់ចុងចម្លើយ**

-គ្មាន ។

## សំអាងហេតុ

ផ្អែកតាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងនានា យល់ឃើញថា៖

១.ការទាមទារ សុំអោយតុលាការចេញសាលក្រមសម្រេចក្នុងពាក្យបណ្តឹងតវ៉ារបស់តតិយជន ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់តតិយជនឈ្មោះ [redacted] ថៃ ដែលមានលោកមេធាវីឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិគឺខ្លឹមសារនៃការទាមទារ មិនត្រឹមត្រូវ តាមមាត្រា៣៦៥ និងមាត្រា៣៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ គប្បីតុលាការច្រានចោលការទាមទារ ក្នុងពាក្យបណ្តឹងតវ៉ា របស់តតិយជន ។

២.ដីកាសម្រេចរក្សាការពារលេខ ២៥១ "ក១"ដរ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ តុលាការបានសម្រេចរឹបអូសជាបណ្តោះអាសន្ននូវចលនវត្ថុ(រថយន្ត) ពាក់ស្លាកលេខភ្នំពេញ 2AG-5180 ម៉ាក TOYOTA CAMRY ពាក់ស្លាកលេខ ភ្នំពេញ ២AG-៥១៨០ ពណ៌ទឹកមាស ផលិតឆ្នាំ២០០៧ លេខតួ ០០៨៧៤៤ លេខម៉ាស៊ីន ២៣២២៤៦



Scanned with CamScanner

របស់កូនបំណុលឈ្មោះ [redacted] ហឿន , ឈ្មោះ [redacted] សារី និងឈ្មោះ [redacted] វិបុល ដោយម្ចាស់បំណុលមានសិទ្ធិទំនាក់ទំនងគតិយុត្ត សិទ្ធិលើបំណុល ចំពោះកូនបំណុល ។ ដីកាសម្រេចរក្សាការពារនេះបានអនុវត្តរួចហើយ ។

៣.តតិយជនឈ្មោះ [redacted] ថៃ បានធ្វើពាក្យតវ៉ា ដោយអះអាងនូវអង្គហេតុថា កូនបំណុលឈ្មោះ [redacted] ហឿន,ឈ្មោះ [redacted] ចាន់សារី និងឈ្មោះ [redacted] វិបុល បានទិញរថយន្តបង់រំលោះមានការប្រាក់ តែគ្មានទ្រព្យបញ្ចាំនោះទេ ។ ការសម្រេចរឹបអូសរថយន្តនោះធ្វើអោយប៉ះពាល់ផលប្រយោជន៍របស់ខ្លួន តែខ្លឹមសារនៃការទាមទារអោយតុលាការចេញសាលក្រម មិនត្រឹមត្រូវតាមមាត្រា៣៦៥ និងមាត្រា ៣៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីនោះទេ ។

៤.តាមមាត្រា៣៦៥ និងមាត្រា ៣៦៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ក្នុងបណ្តឹងតវ៉ារបស់តតិយជន គឺត្រូវសរសេរថា "ការអនុវត្តដោយបង្ខំរបស់ម្ចាស់បំណុលនៃការអនុវត្តដោយផ្អែកលើលិខិតអនុវត្ត ចំពោះវត្ថុដែលជាកម្មវត្ថុសិទ្ធិរបស់តតិយជន ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់មិនត្រូវបានអនុញ្ញាត" ក្នុងករណីដែលតុលាការទទួលស្គាល់ការទាមទាររបស់តតិយជនក្នុងសាលក្រមចុងក្រោយ ទើបតុលាការអាចលុបចោលការអនុវត្តដីកាសម្រេចរក្សាការពារនោះបាន ។

៥.ប្រាក់ប្រដាប់ក្តីគប្បីអនុវត្តតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-ច្រានចោលការទាមទារទាំងអស់ក្នុងពាក្យបណ្តឹងតវ៉ា ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០ របស់ដើមចោទឈ្មោះ [redacted] ថៃ ដែលមានលោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះត្រូវបានប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១ ។

គូភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេល០១(មួយ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលបានការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា ៖ [redacted]

**បានឃើញ**

**ចៅក្រម**

[redacted]

"បានចម្លងចេញពីសាលក្រមដើមត្រឹមត្រូវហើយ"

ថ្ងៃព្រហស្បតិ៍ ៧កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ,ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner